ISO33Ko
TSL Box 4

# ផ្នែក "ក"

ក្បាលម៉ាស៊ីន ដឹកនាំមាន ៣ នាក់ :

១ . អ៊ុម ឈុំ អតីតនាយទាហានសត្តិ ២ កង៧ល ១៣ៗ
ជាមេ បង្កប់នៅភូមិ សែនដី ៗ

២ . ស៊ឹម មុី ប្រធានសហករណ៍ ក្រុមទី ៣ ភូមិទ្រៃព្រកោះ
ជាមេរង បង្កប់ខ្លួននៅក្នុងសហករណ៍ ៗ

៣ . - ស៊ុក . ម៉ិច អតីតប្រធានវត្ត ត្រពាំងគង ជាមេរង
បង្កប់ខ្លួននៅ ក្នុងទ្រៃព្រ សង់ទែក ៗ

# ប្រវត្តិ · អ៊ុម · ឈុំ

ក . ផ្ទាល់ខ្លួន :

. អាយុ ៤៥ ឆ្នាំ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

. កើតនៅភូមិ សែនដី ឃុំសែនដី ស្រុក ៥២ តំបន់ ៣៣ ។

. ក្រោយ ១៧.៤.៧៥ កសិករថ្មី ភូមិសែនដី ឃុំសែនដី ។

ខ . ប្រវត្តិរូប :

៥៧ - ៧៥ : សក្តិ ២ កងពល ១៣ កំពង់ស្ពឺ ។

៦៩ : ចូល សេអ៊ីអា នៅបន្ទាយទេវាងគោ កំពង់ស្ពឺ ។

. អ្នកនាំចូល និង អ្នកទទួលស្គាល់ ភ្លាប់ពុំបាន ។

. ថានៈ និង ប្រាក់ខែ ភ្លាប់ពុំបាន ។

. ដឹងព្រោះ អ៊ុម ឈុំ និយាយប្រាប់ នៅពេលដែលគេ-

អូសទាញខ្លួន ឱ្យធ្វើចោរព្រៃ . ។

១៧.៤.៧៥: ជំលៀសទៅភូមិសែនដី ឃុំសែនដី ស្រុក ៥២ ។

៥.៧៥ : ផ្ដើមអនុវត្តផែនការចោរព្រៃ ។

បច្ចុប្បន្ន : បង្កប់ខ្លួននៅ ភូមិសែនដី ឃុំសែនដី ។

គ . ប្រវត្តិ ទាក់ទង អ៊ុម ឈុំ និង ថោង យាន .

. អ៊ុម ឈុំ ត្រូវជាឪពុកមា ថោង យាន ។

១៩៧៣ : សហការ ជាមួយ អ៊ុម ឈុំ ចាប់បានខ្មែរក្រហម ២ នាក់ នៅភ្នំតិល ...

៥.៧៥ : អ៊ុម ឈុំ មកអូសទាញ ឱ្យចូលចោរព្រៃម្ដង តែថោង យានប្រកែកពុំព្រម ។

ឃ . សកម្មភាព អ៊ុម . ឃុំ :

អ៊ុម ឃុំ ជា សេអ៊ីអា ទទួលភារៈដឹកនាំពួកចោរទីព្រៃ ទាំងអស់នៅ - ភូមិសែនដី ឃុំ សែនដី ។

កន្លងមក អ៊ុម ឃុំ បានធ្វើសកម្មភាព :

១. ឃោសនា សំងាត់ ខ្សិបខ្សៀវ ជាមួយកសិករថ្មីឱ្យប្រឆាំង ប.វ ។

ខ្លឹមសារ ដែលវាលើក គឺ :

- បញ្ហា បំបិត សាសនា ។
- បញ្ហា បង្ខិតបង្ខំ ប្រ.ជ ឱ្យធ្វើការច្រើន ហូបមិនឆ្អែត ។
- បញ្ហា បិតសាលារៀន ។
- សិទ្ធ សេរីភាព របស់ប្រជាជន ។

២. បាត់តាំង :

៨.៧៥ ដល់: ដឹកនាំ ប្រជុំ បក្សពួកចោរទីព្រៃនៅទីព្រៃ សង់ទុក ២ដង

១.៧៦ : ដើម្បីលើកផែនការ ប្រឆាំង ប.វ ។

. លើកទី ១ មានគ្នាតែ ៩ នាក់ គឺ :

| | |
|---|---|
| ១ . អ៊ុម ឃុំ | ៥ . សួយ តាំ |
| ២ . ស៊ឹម ម៉ី | ៦ . តេង ទ្រី |
| ៣ . ស៊ុក ម៉ុច | ៧ . .. តំ |
| ៤ . នៅម៉ា | ៨ . ម៉ា ស៊ុម |
| | ៩ . ថោង យាន ។ |

ទំលីកទី ២ : ពួកថៅទទ្រើព្រៃ ទាំងអស់ ។

១.៧៦ កលាងកម្លាំងបាន ៩ នាក់ គឺ :

១. ស៊ុក ម៉ិច រត់ចូលទ្រើព្រៃ សង់ទេក ។

២. ស៊ឹម មុី ប្រធានសហកណ្ឌ ក្រុមទី ៣ ភូមិទ្រៃពកោះ ។

៣. នៅ ម៉ា កសិករចាស់ ភូមិរលាំងចេក ។ រត់ចូលទ្រើព្រៃ ។

៤. នៅ ខែង ភូមិ សុបិន ។

៥. ចាប វ៉ុន ភូមិត្រពាំងគង ។

៦. អ៊ុំ ស៊ូ ភូមិត្រពាំងគង ។ រត់ចូលទ្រើព្រៃ ។

៧. ជិន ឃីម ភូមិ បង់បត់ ។

៨. ដា ចន ភូមិត្រពាំងខែង ។

៩. ឡេញ ទេត ភូមិត្រពាំងខែង ។ រត់ចូលទ្រើព្រៃ ។

ង. ភិនភាគ :

មានអាយុ ក្រអាញ ។ កំពស់ ១.៦០ ម ។ សំបុរសណ្តែកបាយ ។

សម្លេងស្អក ។ និយាយមួយ ៗ ។ ដំណើរថ្ពក ។

មានស្លាកស្នាមនៅដើមដៃ ខាងឆ្វេង ជិតស្មា • មុតកាំបិត • ។

ច. ប្រពន្ធ - កូន :

ឈ្មោះ ណែម ។

មានកូនប្រុស ២ នាក់ ។ ប្រុសទាំង ពីរតូច ៗ។

បច្ចុប្បន្ន : នៅជាមួយប្តី ភូមិសែនដី ។

• ន.ប ក្ដាប់ ពុំបាន ។

# ផ្នែក . ១ .

## ខ្វែ អ៊ុម . ឈុំ

១ . អតីត សក្ខិ ២ កង៣ល ១៣ ។

មេចោរព្រៃធំ បង្កប់ក្នុងភូមិ សែនដី ។

ក្តាប់កូនចោរ ក្នុងភូមិផង និង ក្នុងព្រៃផង ។

២ . បច្ចុប្បន្ន : វាក្តាប់ ផ្ទាល់ ៦ នាក់ :

១ . សុក . ម៉ិច មេចោរពួនព្រៃ .

២ . ស៊ីម ម៉ី បង្កប់ក្នុងភូមិព្រៃកោះ "ប្រធានសហករណ៍ .

៣ . នៅ ទ៉ែង បង្កប់ក្នុងភូមិ សុបិន .

៤ . ចាប វ៉ន បង្កប់ក្នុងភូមិ ត្រពាំងគង .

៥ . ជិន យឹម បង្កប់ក្នុងភូមិ បង់បត់ .

៦ . ជា ចន បង្កប់ក្នុងភូមិ ត្រពាំងវែង .

១ . ស៊ុក . មិុច

២ . ស៊ឹម ម៊ី

បានរាយការណ៍ជូន ក្នុងផ្នែក . ក្បាលម៉ាស៊ីន . ហើយ ។